# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

# បញ្ញើ និង ការជួលចំណាត




រៀបចំដោយ៖ លោក មួង សៀងលី
សាស្ត្រាចារ្យនៃមហាវិទ្យាល័យនីតិសាស្ត្រ និងវិទ្យាសាស្ត្រនយោបាយ

Phnom Penh : 07/07/2016



fppt.com

# មាតិកា

១. និយមន័យនៃបញ្ញើ

២. ធាតុសំខាន់ៗនៃបញ្ញើ

៣. ប្រភេទនៃបញ្ញើ

៤. លក្ខណៈទូទៅ និងលក្ខណៈដោយឡែកនៃបញ្ញើ

៥. សិទ្ធិ និងករណីយកិច្ចរបស់ភាគី

៦. អត្ថន័យនៃការជួលចំណត

៧. ការបង្កើតកិច្ចសន្យាជួលចំណត

៨. អំពីទីតាំងចំណត និង ប័ណ្ណចំណត

៩.សិទ្ធិ និងករណីករណីយកិច្ចចម្បងរបស់ភាគីជួលចំណត

១០. លក្ខណៈខុសគ្នារវាងបញ្ញើយានជំនិះ និងការជួលចំណត

១១.ករណីសិក្សា

# បញ្ញើ

- **និយមន័យ**
  - បញ្ញើ សំដៅដល់កិច្ចសន្យាដែលភាគីម្ខាង ជាអ្នកទទួលបញ្ញើ សន្យាទទួលយកវត្ថុបញ្ញើ ពីភាគីម្ខាងទៀតជាអ្នកផ្ញើ មករក្សាទុកក្នុងអំឡុងពេលដែលបានកំណត់ ហើយនៅក្រោយពេលដែលអំឡុងពេលរក្សាទុកនោះបានបញ្ចប់ ត្រូវសងវត្ថុដដែលនោះ ទៅឲ្យអ្នកផ្ញើវិញ។ ( CC#669 )




By Mourn Siengly
Fb: Sieng Lee

# ធាតុសំខាន់ៗនៃបញ្ញើ

១
ឆន្ទៈព្រមព្រៀង
អំពីបញ្ញើ
( CC#៦៦៩, CC#៦៧១ )

២
ការផ្ទេរការកាន់កាប់ចំពោះវត្ថុ
( CC#៦៧០ )

៣
ការទទួលយកដើម្បីរក្សាទុក
( CC#៦៧០, CC#៦៧៣ )

៤
កម្មវត្ថុ
ជាវត្ថុរូបិយ
និងស្របច្បាប់

# លក្ខណៈនៃធាតុសំខាន់នីមួយៗ (១)

១

## ឆន្ទៈព្រមព្រៀងអំពីបញ្ញើ

ជាទូទៅ
បង្ហាញ
ឆន្ទៈតណ្ហាភាព

ជាទូទៅ
បង្ហាញ
ឆន្ទៈតណ្ហាភាព

**អ្នកផ្ញើ**

មានឆន្ទៈផ្ទេរបន្ទុកហានិភ័យទៅអ្នកទទួលបញ្ញើ ដោយការផ្ទេរការកាន់កាប់។

**អ្នកទទួលបញ្ញើ**

មានឆន្ទៈទទួលយកបន្ទុកហានិ-ភ័យ ដោយរក្សាទុក និងគ្រប់គ្រងវត្ថុ ដើម្បីប្រយោជន៍របស់អ្នកផ្ញើ។

# លក្ខណៈនៃធាតុសំខាន់នីមួយៗ (២)

## ២

### ការផ្ទេរកាន់កាប់

- **ការប្រគល់ជាក់ស្តែង**
  - អ្នកផ្ញើប្រគល់វត្ថុទៅអ្នកទទួលបញ្ញើកាន់កាប់។
- **ការផ្ទេរកាន់កាប់ដោយសង្ខេប**
  - អ្នកទទួលបញ្ញើកំពុងកាន់កាប់វត្ថុបញ្ញើនោះស្រាប់។ ហេតុនេះភាគីគ្រាន់តែមានការព្រមព្រៀងគឺបង្កើតអានុភាព។
- **ការផ្ទេរការកាន់ដោយបញ្ជា**
  - វត្ថុកាន់កាប់ដោយតតិយជន ត្រូវបានប្រគល់ទៅអ្នកទទួលបញ្ញើ តាមបញ្ជារបស់អ្នកផ្ញើ។

# ស្ថានភាពដែលសន្មត់ថា មានការផ្ទេរការកាន់កាប់

## ១.ការប្រគល់សោរ ឬឧបករណ៍បញ្ជាផ្សេងទៀត




- ចំពោះដីមានរបង អាគារ (CC#១៥០ )រថយន្ត និងគ្រឿងយន្តធំៗផ្សេងទៀត ដែលត្រូវគ្រប់គ្រងដោយប្រើប្រាស់សោរ ឬឧបករណ៍បញ្ជា...
  - Michael H. Rubin, *Bailment and Deposit in Louisiana*, 35 La. L. Rev. (1975)
    Available at: http://digitalcommons.law.lsu.edu/lalrev/vol35/iss4/8
  - Handout of Bailment prepare by Professor Donald Carper of CALIFORNIA STATE UNIVERSITY, SACRAMENTO
  - សាលក្រមតុលាការ TOKYO ចុះថ្ងៃទី ២៧ ខែកញ្ញា ឆ្នាំ១៩៩៦
  - សាលដីកាសាលាឧទ្ធរណ៍ OSAKA ចុះថ្ងៃទី ២៨ ខែកញ្ញា ឆ្នាំ២០០០

## ២.ប្រគល់ការភ្ជាប់ទុកវត្ថុជាក់ស្តែង



- ចំពោះវត្ថុ ឬយានជំនិះផ្សេងៗដែលអាចបំលាស់ទីបានដោយងាយស្រួល ដោយមិនប្រើ ឬពុំចាំបាច់ប្រើសោរ ឬឧបករណ៍បញ្ជា ។


By Mourn Siengly
Fb: Sieng Lee

# លក្ខណៈនៃឃ្លាំងសំខាន់នីមួយៗ (៣)

## ៣ ការទទួលយក ដើម្បីរក្សាទុក

- កន្លែងផ្ញើមានទ្វារច្រកចេញចូល បិទ បើក និងរបងហ៊ុំព័ទ្ធជានាសុវត្ថិភាពបានគ្រប់គ្រាន់។
- កន្លែងផ្ញើមានសន្តិសុខយាម និងត្រួតពិនិត្យ ការយកចូល និងយកចេញ។
- អ្នកទទួលបញ្ញើប្រើប្រាស់ សំបុត្រផ្ញើ ឬលិខិតបញ្ជាក់ផ្សេងៗ ដើម្បីធ្វើកំណត់សម្គាល់ដាក់លាក់ អំពីអត្តសញ្ញាណនៃវត្ថុនោះ ជាមួយអ្នកផ្ញើ។
- អ្នកទទួលបញ្ញើប្រើប្រាស់មធ្យោបាយ ឬមានការរៀបចំផ្សេងៗទៀត ក្នុងការធានាឲ្យបាននូវសុវត្ថិភាពនៃវត្ថុបញ្ញើ។

# លក្ខណៈនៃធាតុសំខាន់នីមួយៗ (៣)

## ៤ កម្មវត្ថុ (សេចក្ដីកំណត់ CC#669)

+ វត្ថុរូបិយ (ចលនវត្ថុ និងអចលនវត្ថុ)
  - ចលនវត្ថុ អ្នកទទួលបញ្ញើរក្សាទុក និងគ្រប់គ្រង និងអនុវត្តផងដែរ ចំពោះប្រាក់ក្នុងស្រោមសំបុត្រ។ ចំពោះប្រាក់មិនកំណត់ដាក់លាក់ ឬមិនដាក់ក្នុងស្រោមសំបុត្រ គឺជាបញ្ញើបរិភោគ។
  - អចលនវត្ថុ អ្នកទទួលបញ្ញើរក្សាទុក ដោយមិនគ្រប់គ្រង។ ករណីដែលបន្ថែមនូវការគ្រប់គ្រង អាចបកស្រាយបានថា ជាអាណត្តិ។
+ សិទ្ធិលើបំណុល ដែលមានលិខិត ឬឯកសារបញ្ជាក់ (ឧបករណ៍ដែលអាចជួញដូរបាន)
+ ឧ. ប្រព័ន្ធការពាររក្សាទុកបញ្ញើភាគហ៊ុនរបស់វិនិយោគិន។
+ ស្របច្បាប់

# ប្រភេទនៃបញ្ញើ

| | | | |
|---|---|---|---|
| **បញ្ញើ** | **បញ្ញើធម្មតា**<br>( CC#669 ដល់ CC#688 ) | | |
| | **បញ្ញើពិសេស**<br>( CC#689 ដល់ CC#698 ) | | **បញ្ញើរួមបញ្ចូល**<br>( CC#689 ) |
| | | | **បញ្ញើបរិភោគ**<br>( CC#690 & CC#691 ) |
| | | | **វិសុណ្ណាប័ន**<br>( CC#692 & CC#698 ) |

បញ្ជាក់ ៖ បញ្ញើរួមបញ្ចូល , បញ្ញើបរិភោគ និងវិសុណ្ណាប័ន អនុវត្តបញ្ញត្តិទូទៅ ( CC#669 ដល់ CC#688 ) ក្នុងទំហំដែលមិនផ្ទុយនឹងបទប្បញ្ញត្តិពិសេសទាំងនោះ។

By Mourn Siengly-Fb: Sieng Lee

# ១.បញ្ញើធម្មតា ( CC#669 ដល់ CC#688 )

- ក្រៅពីបញ្ញើពិសេស គឺបញ្ញើធម្មតា។
- អត្ថន័យនៃបញ្ញើធម្មតា សូមមើល Slide N.2។
- <u>ឧទាហរណ៍៖</u>







ក បានប្រគល់ឡាន និងសោរឡានទៅឲ្យ ខ ដើម្បីរក្សាទុកក្នុង រយៈពេល ៥ ថ្ងៃ មុនពេល ក ចាកចេញទៅប្រទេសថៃ។ ខ បានគ្រប់គ្រង និងរក្សាទុកឡាននោះ នៅក្នុងឃ្លាំងអាជីវកម្មផ្ញើឡានរបស់គាត់ ដោយមានសន្តិសុខ យាម និងគ្រប់គ្រងថែរក្សា។

# ២.បញ្ញើរួមបញ្ចូល ( CC#689 )

- ប្រសិនបើអ្នកទទួលបញ្ញើ ទទួលបញ្ញើនូវវត្ថុដែលមានប្រភេទដូចគ្នា ពីអ្នកផ្ញើច្រើននាក់ ហើយអាចរក្សាទុករួមបញ្ចូលគ្នា ដោយមិនបាច់បែងចែកវត្ថុបញ្ញើនោះ តាមកិច្ចសន្យា អ្នកផ្ញើនីមួយៗ មានសិទ្ធិទៅតាមសមាមាត្រនៃចំនួនវត្ថុផ្ញើរបស់ខ្លួន ចំពោះវត្ថុទាំងមូល ដែលត្រូវបានរក្សាទុកដោយរួមបញ្ចូលគ្នា ។

- **ឧទាហរណ៍៖**

- ក បានផ្ញើ អង្ករផ្កាម្លិះ ៥០០គីឡូ រក្សាទុកនៅក្នុងឃ្លាំងស្តុកអង្កររបស់ A
- ខ បានផ្ញើ អង្ករផ្កាម្លិះ ៣០០គីឡូ រក្សាទុកនៅក្នុងឃ្លាំងស្តុកអង្កររបស់ A
- គ បានផ្ញើ អង្ករផ្កាម្លិះ ៦០០ គីឡូ រក្សាទុកនៅក្នុងឃ្លាំងស្តុកអង្កររបស់ A

# បញ្ញើរួមបញ្ចូល

## អ្នកផ្ញើច្រើននាក់




By Mourn Siengly-Fb: Sieng Lee

# ៣.បញ្ញើបរិភោគ ( CC#690 & CC#691 )

- បញ្ញើបរិភោគ នៅក្នុងកិច្ចសន្យាបញ្ញើ បើបានព្រមព្រៀងឲ្យអ្នកទទួលបញ្ញើ អាចបរិភោគវត្ថុបញ្ញើបាន អ្នកទទួលបញ្ញើ មានករណីយកិច្ចសងវត្ថុដែលមានប្រភេទ និងចំនួនដូចគ្នានឹងវត្ថុបញ្ញើនោះ ។

- បញ្ញត្តិស្តីពីការខ្ចីបរិភោគ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះបញ្ញើបរិភោគដែលបានកំណត់នៅក្នុងមាត្រា ៦៩០ ខាងលើនេះ ។ ប៉ុន្តែក្នុងករណីនេះប្រសិនបើគ្មានកំណត់អំឡុងពេលសងនៅក្នុងកិច្ចសន្យាទេ អ្នកផ្ញើអាចទាមទារឲ្យសង នៅពេលណាក៏បាន ។

# បញ្ញើបរិភោគ



**ឧទាហរណ៍៖**

- ក បានផ្ញើប្រាក់ចំនួន ១០០០ ដុល្លានៅធនាគារ ABC ដោយទទួលបានការប្រាក់ ៣% ក្នុងមួយឆ្នាំ ។ ធនាគារអាចយកប្រាក់របស់ ក ទៅផ្តល់ជាឥណទានឲ្យអតិថិជនរបស់ខ្លួនបាន។ ធនាគារ ABC អាចសងប្រាក់ចំនួន ១០០០ ដុល្លា ជាក្រដាសប្រាក់ផ្សេងជំនួសប្រាក់ដើមរបស់ ក ។

# ៤.វិសុណ្ឋាប័ន ( CC#692 & CC#698 )

## ១. វិសុណ្ឋាប័នតាមឆន្ទៈភាគី

- វិសុណ្ឋាប័ន សំដៅទៅលើកិច្ចសន្យាមួយ ដែលបុគ្គលច្រើននាក់ មានវិវាទទៅលើសិទ្ធិកាន់កាប់ ឬកម្មសិទ្ធិ នៃវត្ថុ យកវត្ថុដែលជាកម្មវត្ថុនៃវិវាទនេះ ផ្ញើទុកនៅតតិយជនដែលហៅថា វិសុណ្ឋាបនិក រហូតដល់ពេលអ្នកដែលមានសិទ្ធិនោះត្រូវបានកំណត់ជាស្ថាពរ ។
- បើគ្មានការយល់ព្រមពីបុគ្គលដែលអះអាងអំពីសិទ្ធិទាំងអស់គ្នាទេ បញ្ញើនៃវត្ថុដែលជាកម្មវត្ថុនៃវិវាទ ពុំមានសុពលភាពឡើយ។

## ២. វិសុណ្ឋាប័នតាមការបង្គាប់របស់តុលាការ

- ក្នុងករណីដែលមានសិទ្ធិកាន់កាប់វត្ថុ ឬកម្មសិទ្ធិនៃវត្ថុ ត្រូវបានយកជាកម្មវត្ថុនៃវិវាទនៅក្នុងតុលាការ ទោះបីជាគ្មានការព្រមព្រៀងរវាងភាគីក៏ដោយ តុលាការអាចឲ្យតតិយជន រក្សាទុកវត្ថុដែលជាកម្មវត្ថុនៃវិវាទបាន។

# ចិស្សុណ្ណាប័នតាមឆន្ទៈភាគី

❖ ឧទាហរណ៍៖

ក និង ខ មានវិវាទអំពីកម្មសិទ្ធិលើរថយន្ត (A) ដែលកាន់កាប់ដោយ គ (អ្នកលក់) ។ ក ខ និង គ បានឯកភាពគ្នា ប្រគល់រថយន្ត (A) ឲ្យទៅ Z (វិសុណ្ណាបនិក) ដើម្បីគ្រប់គ្រង និងរក្សាទុក រហូតដល់ពេលមានសាលក្រមកំណត់អំពី អត្ថិភាពនៃសិទ្ធិស្ពាពររបស់ភាគីនៃវិវាទ ទើប Z ត្រូវសងរថយន្ត (A) នោះ ទៅឲ្យអ្នកដែលមានសិទ្ធិ។

ភាគី៖ អ្នកផ្ញើៈ ក និង ខ , អ្នកទទួលបញ្ញើៈ Z (វិសុណ្ណាបនិក)។

# វិសុណ្ណាប័នតាមឆន្ទៈភាគី




យល់ព្រមប្រគល់វត្ថុជាកម្មវត្ថុវិវាទទៅវិសុណ្ណាបនិក

គ្រប់គ្រង និងរក្សាទុក រហូតដល់មានការកំណត់អំពីអត្ថិភាពនៃសិទ្ធិស្ថាពរ

By Mourn Siengly

Fb: Sieng Lee

# វិសុណ្ឋាប័នតាមការបង្គាប់របស់តុលាការ

- ឧទាហរណ៍៖

ក និង ខ មានវិវាទអំពីកម្មសិទ្ធិលើរថយន្ត (A) ដែលកាន់កាប់ដោយ គ (អ្នកលក់) ។ ក ខ និង គ គ្មានការឯកភាពគ្នាក្នុងការបង្កើតវិសុណ្ឋាប័នឡើយ។ ហេតុនេះ ក បានស្នើសុំឲ្យតុលាការបង្គាប់ឲ្យ គ ប្រគល់រថយន្ត(A) ឲ្យទៅ Z ដើម្បីគ្រប់គ្រង និង រក្សាទុក។ តុលាការបានសម្រេចឲ្យតតិយជន Z ធ្វើជាវិសុណ្ឋាបនិក តាមការស្នើសុំរបស់ ក រហូតដល់ពេលមានសាលក្រមកំណត់អំពីអត្ថិភាពនៃសិទ្ធិស្ពាពររបស់ភាគីនៃវិវាទ ទើប Z ត្រូវសងរថយន្ត (A) នោះ ទៅឲ្យអ្នកដែលមានសិទ្ធិ។

# លក្ខណៈទូទៅនៃបញ្ញើ

**កិច្ចសន្យាកណ្ដិក**

(CC#៦៧០) ជាគោលការណ៍ទូទៅ បញ្ញើនឹងមិនបង្កើតអានុភាពឡើយ ប្រសិនបើគ្មានការផ្ទេរកាន់កាប់ពីអ្នកផ្ញើ និងអ្នកទទួលបញ្ញើ បានទទួលយកវត្ថុនោះមកកាន់កាប់។

**កិច្ចសន្យាមុធា**

(CC#៦៧៥) ជាគោលការណ៍ បញ្ញើ ធ្វើឡើងដោយមិនយកកម្រៃឡើយ។ អ្នកទទួលបញ្ញើ គឺសកម្មភាពគ្រប់គ្រង និងរក្សាទុក ដើម្បីជាផលប្រយោជន៍របស់អ្នកផ្ញើ។

**កិច្ចសន្យាឯកតោភាគី**

(CC#៦៧៥) ជាគោលការណ៍ បញ្ញើបង្កើតឡើងដោយមិនយកកម្រៃ ហេតុនេះ មានតែអ្នកទទួលបញ្ញើប៉ុណ្ណោះ មានកាតព្វកិច្ចចំពោះអ្នកផ្ញើ។ ករណីនេះ អ្នកផ្ញើ ពុំមានកាតព្វកិច្ចតបចំពោះអ្នកទទួលបញ្ញើនោះទេ។

**កម្មវត្ថុរូបិយ ស្របច្បាប់**

(សេចក្ដីកំណត់ CC#៦៦៩ & CC#៣៥៤) កម្មវត្ថុ រូបិយ និងស្របច្បាប់ ។

By Mourn Siengly-Fb: Sieng Lee

# លក្ខណៈដោយឡែកនៃបញ្ញើ

**កិច្ចសន្យាព្រមព្រៀង**

(CC#៦៧១) ករណីបញ្ញើនាពេលអនាគត បញ្ញើនឹងបង្កើតអានុភាព បន្ទាប់ពីមានការព្រមព្រៀងបញ្ញើ តែភាគីអាចដកការព្រមព្រៀងនោះចេញនៅពេលណាក៏បានដែរ រហូតដល់ពេលដែលបានប្រគល់វត្ថុនៃបញ្ញើ។

**កិច្ចសន្យាមូលា**

(CC#៦៧៥) បកស្រាយបដិលោមវិធី។

(CC#៦៦៩) អ្នកទទួល បញ្ញើអាចទាមទារកម្រៃបាន។

**កិច្ចសន្យាអញ្ញមញ្ញ**

(CC#៦៧៥) បញ្ញើយកកម្រៃ គឺជាកិច្ចសន្យាបង្កើតឲ្យភាគីទាំងសងខាងមានកាតព្វកិច្ចចំពោះគ្នាទៅវិញទៅមក។ ករណីនេះ អ្នកផ្ញើ មានកាតព្វកិច្ចបង់កម្រៃតបចំពោះកាតព្វកិច្ចរក្សាទុករបស់អ្នកទទួលបញ្ញើ។

**កម្មវត្ថុអរូបិយ**

(សេចក្តីកំណត់ CC#៦៦៩ & CC#៣៥៤) សិទ្ធិលើបំណុល ដែលមានលិខិត ឬឯកសារបញ្ជាក់ ជាអាទិ៍ ឧបករណ៍ដែលអាចជួញដូរបាន ។

By Mourn Siengly-Fb: Sieng Lee

# សិទ្ធិរបស់អ្នកផ្ញើ

១.ដកការព្រមព្រៀងចំពោះបញ្ញើនាពេលអនាគត CC#671

២.ទាមទារសំណងខូចខាត ចំពោះកំហុស CC#671/2 &CC#674/1 និងទោះបីជាគ្មានកំហុស ក្នុងករណីមួយចំនួន CC#674/2.3។

៣.ទាមទារឲ្យសងវត្ថុនៃបញ្ញើ CC#680

៤.ទទួលការសងដែលបានធ្វើឧបាទេសកម្ម

៥.ទទួលផល ឬចំណូលដែលកើតចេញពីវត្ថុបញ្ញើ CC#683

៦.ទទួលបានការប្រាក់ ចំពោះបញ្ញើបរិភោគ CC#691

By Mourn Siengly-Fb: Sieng Lee

# ករណីយកិច្ចរបស់អ្នកផ្ញើ

(CC#676)
- រាយការណ៍អំពីប្រភេទ និងតម្លៃនៃវត្ថុបញ្ញើ ករណីផ្ញើប្រាក់ ឧបករណ៍ដែលអាចជួញដូរបាន ឬវត្ថុដែលមានតម្លៃខ្ពស់។

(CC#685.1)
- ទទួលបន្ទុកសោហ៊ុយនៃការសងបញ្ញើ ចំពោះបញ្ញើមិនយកកម្រៃ

(CC# 686)
- សងសោហ៊ុយចាំបាច់ក្នុងការរក្សាទុក

(CC#686)
- ទទួលបន្ទុកបង្ហាញអំពីកំហុស ឬភាពគ្មានកំហុស ករណីដែលអ្នកទទួលបញ្ញើ មានសិទ្ធិទាមទារសំណងនៃការខូចខាត.

(CC#689)
- បង់កម្រៃសេវាផ្ញើវត្ថុ ចំពោះបញ្ញើយកកម្រៃ

# សិទ្ធិរបស់អ្នកទទួលបញ្ញើ

| | |
|---|---|
| ៦៦៩, ៦៩៥ | • ទាមទារកម្រៃនៃសេវាបញ្ញើ |
| ៦៧១ | • ដកការព្រមព្រៀងចំពោះបញ្ញើនាពេលអនាគត |
| ៦៧២ | • សិទ្ធិសងវត្ថុបញ្ញើទៅអ្នកផ្ញើវិញទោះបីអ្នកផ្ញើគ្មានកម្មសិទ្ធិលើវត្ថុក៏ដោយ |
| ៦៧៣.២ | • សិទ្ធិប្រើប្រាស់វត្ថុបញ្ញើ បើមានការយល់ព្រមពីអ្នកផ្ញើ |
| ៦៨១ | • អាចសងវត្ថុបញ្ញើនៅពេលណាក៏បាន ករណីដែលពុំមានកំណត់ពេលសង |
| ៦៨៦.២ | • សិទ្ធិទាមទារសំណងដែលបណ្ដាលមកពីវត្ថុបញ្ញើដែលមិនមែនជាកំហុសរបស់ខ្លួន |
| ៦៨៨ | • សិទ្ធិឃាត់ទុករបស់អ្នកទទួលបញ្ញើ |

By Mourn Siengly-Fb: Sieng Lee

# ករណីយកិច្ចរបស់អ្នកទទួលបញ្ញើ

| | |
|---|---|
| ៦៧៣.១ | • រក្សាទុកវត្ថុបញ្ញើដោយព្យាយាមយ៉ាងប្រុងប្រយ័ត្នក្នុងមជាអ្នកគ្រប់គ្រងដោយសុចរិត |
| ៦៧៤ | • ទទួលខុសត្រូវ សងការខូចខាត ចំពោះការធ្វើឲ្យបាត់បង់ ឬ បែកបាក់ វត្ថុបញ្ញើ |
| ៦៧៧ | • ត្រូវរក្សាទុកដោយខ្លួនឯង លើកលែងមានការយល់ព្រមពីអ្នកផ្ញើ ចំពោះតតិយជន |
| ៦៧៩ | • ត្រូវជូនដំណឹងអំពីហេតុ ដែលតតិយជនអះអាងអំពីសិទ្ធិចំពោះវត្ថុ ឬ រឹបអូសវត្ថុទៅអ្នកផ្ញើ ដោយគ្មានការយឺតយ៉ាវ |
| ៦៨៤, ៦៩០ | • សងវត្ថុដដែល ដែលបានទទួល (៦៨២, ៦៩៦) ឬ វត្ថុជំនួសចំពោះបញ្ញើបរិភោគ |

(ឥ)

By Mourn Siengly-Fb: Sieng Lee

# ករណីយកិច្ចរបស់អ្នកទទួលបញ្ញើ (ត)

| | |
|---|---|
| ៦៨២.២ | • សងវត្ថុដែលបានធ្វើឧបាទេសកម្ម ទៅអ្នកផ្ញើ |
| ៦៨៣ | • ត្រូវប្រគល់ផល និងចំណូលពីវត្ថុបញ្ញើទៅអ្នកផ្ញើ |
| ៦៨៤, ៦៩០,៦៩១ | • ត្រូវបង់ការប្រាក់ករណីបញ្ញើបរិភោគ |
| ៦៨៥ | • ត្រូវទទួលបន្ទុកសោហ៊ុយនៃការសងវត្ថុ ករណីទទួលបញ្ញើបានផ្លាស់ប្តូរកន្លែងផ្ញើ |

By Mourn Siengly-Fb: Sieng Lee

# សញ្ញាណនៃការណើយកិច្ចគ្រប់គ្រង និងរក្សាទុកវត្ថុ
## នៅក្នុងទំនាក់ទំនងកិច្ចសន្យាផ្សេងៗ និងបញ្ញត្តិច្បាប់




By Mourn Siengly-Fb: Sieng Lee

# ការជួលចំណាត

- **អត្ថន័យនៃការជួលចំណាត**
  - គឺជាកិច្ចសន្យាមួយដែលភាគីម្ខាង ហៅថា ភតិបតី ឲ្យភាគីម្ខាងទៀត ហៅថា ភតិកៈ ប្រើប្រាស់ និងអាស្រ័យផល ពីទីតាំងចំណតណាមួយ ដោយយកថ្លៃ។
- **កម្មវត្ថុនៃការជួល**

  គឺជា អចលនវត្ថុ ក្នុងទំហំនៃចំណែកណាមួយសម្រាប់ចតយានជំនិះ។
- **បញ្ញត្តិនៃឥតសន្យា** ត្រូវយកមកអនុវត្តចំពោះ ការជួលចំណត ។
- **បញ្ញត្តិនៃការខ្ចីប្រើ** ត្រូវយកមកអនុវត្តចំពោះការផ្តល់ការប្រើប្រាស់ និងអាស្រ័យផលទីតាំងចំណតដោយមិនយកកម្រៃ។

# ការបង្កើតកិច្ចសន្យាជួលចំណាត

## ឆន្ទៈព្រមព្រៀងជួលចំណាត

ជាទូទៅ
បង្ហាញ
ឆន្ទៈតណ្ហាភាព

ជាទូទៅ
បង្ហាញ
ឆន្ទៈតណ្ហាភាព

**ភតកៈ (ម្ចាស់យានជំនិះ)**

មានឆន្ទៈប្រើប្រាស់ចំណាត
ដោយបង់ថ្លៃ។

**ភតបតី (ម្ចាស់ចំណាត)**

មានឆន្ទៈផ្ដល់ការប្រើប្រាស់ចំណាត
ដោយទាមទារកម្រៃ។

# ទីតាំងចំណត និងប័ណ្ណចំណត

- ជាទូទៅ ចំណត ពុំមានទ្វារច្រកចេញចូល បិទ បើក និងរបងហ៊ុំព័ទ្ធជានាសុវត្ថិភាពបានគ្រប់គ្រាន់នោះទេ។
- សន្តិសុខនៃទីតាំងចំណត មានភារកិច្ចរៀបចំរបៀបរៀបរយចំណត , ផ្តល់ និង ត្រួតពិនិត្យប័ណ្ណចំណត និងប្រមូលថ្លៃឈ្នួល ។
- ប័ណ្ណចំណត គឺបញ្ជាក់អំពីសិទ្ធិប្រើប្រាស់ចំណត ទៅនឹងយានជំនិះ និងកំណត់អំពីថ្លៃឈ្នួល។

By Mourn Siengly-Fb: Sieng Lee

# ការជួលចំណត

- **ឧទាហរណ៍៖** ក បានចតរថយន្តនៅក្នុងទីតាំងចំណតរបស់ផ្សារទំនើប ១ កន្លែង ហើយ ក បានចាក់សោរទ្វារឡានទាំងអស់ និងបានយកសោរទៅតាមខ្លួន ហើយ ក បានបង់ប្រាក់ថ្លៃជួលចំណតនោះ ក្នុង ១ម៉ោង ចំនួន ២០០០៛ តាមការទាមទាររបស់ម្ចាស់ចំណត។





# សិទ្ធិ និងករណីកិច្ចចម្បងៗរបស់ភាគីជួលចំណាត

- **ម្ចាស់ចំណាត (ភតបតី)**
  - សិទ្ធិទាមទារថ្លៃឈ្នួល
  - ករណីយកិច្ចប្រគល់ចំណាតឲ្យទៅអ្នកជួល អាចប្រើប្រាស់ និងអាស្រ័យផលលើចំណាតទៅឲ្យអ្នកជួល
  - ធានាមិនឲ្យមានការរំខានឬវិការៈ ចំពោះការប្រើប្រាស់ចំណាត
- **អ្នកជួលចំណាត (ភតកៈ)**
  - សិទ្ធិប្រើប្រាស់ និងអាស្រ័យផលចំណាត
  - ករណីយកិច្ចបង់ថ្លៃឈ្នួលប្រើប្រាស់ចំណាត
  - ករណីយកិច្ចប្រគល់ចំណាតឲ្យទៅម្ចាស់ចំណាតវិញ

| លក្ខណៈវិនិច្ឆ័យ | បញ្ញើយានជំនិះ | ការជួលចំណាត |
|---|---|---|
| ការផ្ទេរការកាន់កាប់យានជំនិះ | មាន | គ្មាន |
| ការប្រគល់សោររថយន្ត ជាអាទិ៍ | | |
| បញ្ញើកង់ ឬ ម៉ូត ជាអាទិ៍ អាចចល័តបាន ដោយសេរី | អាច | អាចបាន និង មិនអាច ករណីខ្លះ ម្ចាស់ចំណត តម្រូវឲ្យចាក់សោរចង្កូត ឬសោរចាក់កង់ និងផ្តល់សោរនោះទៅអ្នកជួល |
| ការគ្រប់គ្រង និងរក្សាទុកយានជំនិះ | មាន | គ្មាន/ អាចមានខ្លះ តែ មិនគ្រប់គ្រាន់ |
| ប្រើប្រាស់មធ្យោបាយ ឬមានការរៀបចំផ្សេងៗ ក្នុងការធានាឲ្យបាននូវសុវត្ថិភាពនៃយានជំនិះ | | |

(ឥ)

| លក្ខណៈវិនិច្ឆ័យ | បញ្ញើយានជំនិះ | ការជួលចំណត |
|---|---|---|
| កម្រៃ សេវា/ថ្លៃឈ្នួល | អាចមាន ឬគ្មាន | ត្រូវមាន<br>ករណីគ្មាន គឺខ្ចីប្រើ. |
| កម្រិតតម្លៃ សេវា/ថ្លៃឈ្នួល | ខ្ពស់ជាង<br>( មិនដាច់ខាត ) | ទាបជាង<br>( មិនដាច់ខាត ) |
| តាវកាលិកនៃកាតព្វកិច្ច<br>របស់អ្នកទទួលបញ្ញើ និងម្ចាស់ចំណត | គ្រប់គ្រង រក្សាទុក<br>ចលនវត្ថុ ឬអចលនវត្ថុ<br>របស់អ្នកផ្ញើ | ផ្តល់ការប្រើប្រាស់ និង<br>អាស្រ័យផលលើ<br>អចលនវត្ថុ( ចំណត ) |
| ឯកសារបញ្ជាក់ (មិនដាច់ខាត ) | សំបុត្រ ឬប័ណ្ណផ្ញើ | ប័ណ្ណចំណត |
| ខចែង ឬលក្ខខណ្ឌ ក្នុងឯកសារបញ្ជាក់<br>( មិនដាច់ខាត ) | ចែងអំពីការទទួល<br>ខុសត្រូវ | ចែងអំពីការមិនទទួល<br>ខុសត្រូវ និង កំណត់<br>សេវាសម្រាប់ជួល<br>ចំណត |

# ករណីការជួលឬ ខ្ចីប្រើចំណត ឬផ្ញើម៉ូតូ ឬកង់

- **ករណីទី ១ (បញ្ញើ)**
- ឯកសារបញ្ជាក់ ៖ សំបុត្រផ្ញើម៉ូត តែសរសេរអំពីការមិនទទួលខុសត្រូវ
- ការផ្ទេរកាន់កាប់៖ ម៉ូតអាចចល័តបានដោយសេរី
- ទីតាំង៖ មាន ទ្វារ របងហ៊ុំព័ទ្ធ និងមានសុន្តិសុខយាម អាចធានាសុវត្ថិភាពបាន
- តម្លៃ៖ ៥០០ ៛
- **ករណីទី ២ (បញ្ញើ)**
- ឯកសារបញ្ជាក់ ៖ មានសំបុត្រ តែមិនមានសរសេរអំពីការទទួលខុសត្រូវ និងពុំមាន លើកផ្លាកសរសេរបញ្ជាក់អ្វីឡើយ។
- ការផ្ទេរកាន់កាប់៖ ម៉ូតអាចចល័តបានដោយសេរី
- ទីតាំង៖ មាន ទ្វារ របងហ៊ុំព័ទ្ធ និងមានសុន្តិសុខយាម អាចធានាសុវត្ថិភាពបាន
- តម្លៃ៖ ១០០០ ៛

# ករណីការជួលឬ ខ្ចីប្រើចំណត ឬផ្ញើម៉ូតូ ឬកង់

- **ករណីទី ៣ (បញ្ញើ)**
- ឯកសារបញ្ជាក់ ៖ សំបុត្រផ្ញើម៉ូត និងលើកផ្លាកថា ការបាត់បង់ ឬខូចខាត គឺជាការទទួលខុសត្រូវរបស់ម្ចាស់ចំណត
- ការផ្ទេរកាន់កាប់៖ ម៉ូតអាចចល័តបានដោយសេរី
- ទីតាំង៖ ពុំមានសន្តិសុខ និងពុំមានទ្វារ របងហ៊ុំព័ទ្ធ បានត្រឹមត្រូវឡើយ
- តម្លៃ៖ ១000 ៛
- **ករណីទី ៤ (ជួលចំណត)**
- ឯកសារបញ្ជាក់ ៖ ប័ណ្ណចំណត និងសរសេរថាមិនការទទួលខុសត្រូវ និងមានលើកផ្លាកថា ជាចំណត
- ការផ្ទេរកាន់កាប់៖ ម៉ូតអាចចល័តបានដោយសេរី
- ទីតាំង៖ មាន ទ្វារ របងហ៊ុំព័ទ្ធ និងមានសុន្តិសុខយាម
- តម្លៃ៖ ៥00 ៛ សម្រាប់ការជួលចំណត បញ្ជាក់នៅក្នុងសំបុត្រ

# ករណីការជួលឬ ខ្ចីប្រើចំណត ឬផ្ញើម៉ូតូ ឬកង់

- **ករណីទី ៥ (ជួលចំណត)**
- ឯកសារបញ្ជាក់ ៖ សំបុត្រផ្ញើម៉ូត តែសរសេរថាមិនទទួលខុសត្រូវ
- ការផ្ទេរកាន់កាប់៖ គ្មាន (មានចាក់សោរកង់ ហើយសោរនោះរក្សាទុកនៅម្ចាស់ម៉ូតូ)
- ទីតាំង៖ ពុំ មានរបងហ៊ុំព័ទ្ធ ត្រឹមត្រូវ តែមានសុវត្ថិសុខ
- តម្លៃ៖ ៥០០៛
- **ករណីទី ៦ (ខ្ចីប្រើចំណត)**
- ឯកសារបញ្ជាក់ ៖ មិនមានសំបុត្រ
- ការផ្ទេរកាន់កាប់៖ គ្មាន (ម៉ូតូត្រូវបានសាក់សោរករ ឬមានចាក់សោរកង់ ហើយសោរនោះរក្សាទុកនៅម្ចាស់ម៉ូតូ)
- ទីតាំង៖ មានពុំ របងហ៊ុំព័ទ្ធ ត្រឹមត្រូវ តែមានសុវត្ថិសុខ
- តម្លៃ៖ គ្មានកំណត់

# ករណីការជួលឬ ខ្ចីប្រើចំណត ឬផ្ញើរថយន្ត

- **ករណីទី ១ (បញ្ញើ)**
- ឯកសារបញ្ជាក់ ៖ សំបុត្រផ្ញើ តែសរសេរអំពីការមិនទទួលខុសត្រូវ
- ការផ្ទេរកាន់កាប់៖ ប្រគល់សោរ
- ទីតាំង៖ ជាការ៉ាស់ មាន ទ្វារ របងហ៊ុំព័ទ្ធ និងមានសុន្តិសុខយាម
- តម្លៃ៖ ៤០០០៛

- **ករណីទី ២ (ជួលចំណត)**
- ឯកសារបញ្ជាក់ ៖ សំបុត្រផ្ញើ មិនមានសរសេរអំពីការទទួលខុសត្រូវ
- ការផ្ទេរកាន់កាប់៖ មិនប្រគល់សោរ និងបានចាក់សោរទ្វារឡានទាំងអស់
- ទីតាំង៖ មាន របងហ៊ុំព័ទ្ធ និងមានសុន្តិសុខយាមកាម
- តម្លៃ៖ ២០០០ រៀល ចាប់ពីមួយម៉ោងឡើងទៅ

# ករណីការជួលឬ ខ្ចីប្រើចំណាត ឬផ្ញើរថយន្ត

- **ករណីទី ៣ (បញ្ញើមិនយកកម្រៃ)**
- ឯកសារបញ្ជាក់ ៖ មិនមាន
- ការផ្ទេរកាន់កាប់៖ មិនប្រគល់សោរ តែឡានទុកក្នុងចំណតដែលជាបន្ទប់បិទជិត និងចាក់សោរ
- ទីតាំង៖ ផ្ទះសំណាក់ ឬសណ្ឋាគារ មានទ្វាររបងចាក់សោរ របងហ៊ុំព័ទ្ធជិត និងមានសុន្តិសុខយាមកាមជិតដល់
- តម្លៃ៖ មិនយកកម្រៃ

- **ករណីទី ៤ (ខ្ចីប្រើចំណត)**
- ឯកសារបញ្ជាក់ ៖ មិនមានសំបុត្រ
- ការផ្ទេរកាន់កាប់៖ មិនប្រគល់សោរ  និងបានចាក់សោរទ្វារឡានទាំងអស់
- ទីតាំង៖ មិនមាន ទ្វារ របងហ៊ុំព័ទ្ធ តែមានសុន្តិសុខយាមកាម
- តម្លៃ៖ គ្មានការកំណត់តម្លៃ

# ករណីផ្សេងៗ

- **ករណីទី ១ (បញ្ញើមិនយកកម្រៃ)**
- ឯកសារបញ្ជាក់ ៖ សំបុត្រផ្ញើ
- ការផ្ទេរកាន់កាប់៖ អ្នកផ្ញើប្រគល់កាបូប
- ទីតាំង៖ បណ្ណាល័យសិក្សា តម្រូវឲ្យផ្ញើ
- តម្លៃ៖ មិនកំណត់

- **ករណីទី ២ (ខ្ចីច្រើទ្វារដាក់ឥវ៉ាន់)**
- ឯកសារបញ្ជាក់ ៖ មិនមានសំបុត្រផ្ញើ
- ការផ្ទេរកាន់កាប់៖ ភាគីម្ខាងប្រគល់ឥវ៉ាន់ ភាគីម្ខាងប្រគល់សោរទូរដាក់ឥវ៉ាន់
- ទីតាំង៖ ទូរដាក់ឥវ៉ាន់នៅ ផ្សារទំនើប ឬ បណ្ណាគារ ឬកន្លែងស្ទីម សូណា
- តម្លៃ៖ មិនកំណត់

# ឯកសារពិគ្រោះ


- Michael H. Rubin, *Bailment and Deposit in Louisiana*, 35 La. L. Rev. (1975)

  Available at: http://digitalcommons.law.lsu.edu/lalrev/vol35/iss4/8 # **Louisiana Law Review**.
- Liability of Parking Lot Operators for Car Thefts, 20 Wash. & Lee L. Rev. 362 (1963), http://scholarlycommons.law.wlu.edu/wlulr/vol20/iss2/18 # **Wahington and Lee Law Review.**
- Parking Lot - Bailment -Theft by Employee - Goldberg v. Kunz, 10 Md. L. Rev. 185 (1949)

  Available at: http://digitalcommons.law.umaryland.edu/mlr/vol10/iss2/5 # **Maryland Law Review.**
- Editors, Law Review (1941) "Recent Cases: Bailments. Automobiles. Interpretation of Provisions on Parking Lot Ticket Limiting Bailee's Liability," University of Chicago Law Review: Vol. 8: Iss. 4, Article 10.

  Available at: http://chicagounbound.uchicago.edu/uclrev/vol8/iss4/10 # **University of Chicago Law Review**

# ឯកសារពិគ្រោះ

- William V. Vetter, The Parking Lot Cases Revisited: Confusion at or About the Gate, 40 Santa Clara L. Rev. 27 (1999). Available at: http://digitalcommons.law.scu.edu/lawreview/vol40/iss1/2 # **Santa Clara Law Review.**
- អត្ថបទស្តីពី កិច្ចសន្យាបញ្ញើ រៀបចំដោយ៖ មេធាវី អ៊ុំ ប៉ូលី
- សាលក្រមរបស់តុលាការ TOTTORI ចុះថ្ងៃទី ១២-១២-១៩៧៣។
- សាលក្រមរបស់តុលាការ KOCAI ចុះថ្ងៃទី ១២-០៤-១៩៧៦ ។
- សាលក្រមរបស់តុលាការ OSAKA ចុះថ្ងៃទី ១៧-១១-១៩៧៨ ។
- សាលក្រមរបស់តុលាការ KUMAMOTO ចុះថ្ងៃទី ០៥-០៩-១៩៨៥។
- សាលក្រមរបស់តុលាការ TOKYO ចុះថ្ងៃទី ២៧-០៩-១៩៩៦ ។
- សាលដីការបស់តុលាការ OSAKA ចុះថ្ងៃទី ១៨-០៩-២០០០។
- សាលក្រមរបស់តុលាការ TOKYO ចុះថ្ងៃទី ១៤-០៩-២០១៣ ។

# សូមអរគុណ !






fppt.com